# បច្ចេកទេសតមែកប័រជាមួយនឹងគល់ទម្រប័រ

## ១ - សេចក្តីផ្តើម

បច្ចុប្បន្ននេះកសិករ អ្នកធ្វើចំការនៅទូទាំងប្រទេសកម្ពុជា មានការចាប់អារម្មណ៍ខ្លាំងលើការដាំដំណាំប័រ ដោយសារដំណាំនេះងាយស្រួលក្នុងការធ្វើផលិតកម្ម ជាពិសេសមានតម្លៃខ្ពស់នៅទីផ្សារក្នុងស្រុក និងការនាំចេញ។ ផ្ទៃដីដាំដំណាំប័រនៅប្រទេសកម្ពុជាមាននៅខេត្តមួយចំនួនដូចជា៖ មណ្ឌលគិរី រតនៈគិរី បាត់ដំបង និងពោធិ៍សាត់ ដែលកសិករ អ្នកធ្វើចំការកំពុងតែពង្រីកការធ្វើផលិតកម្មបន្ថែមទាំងខ្នាត តូច មធ្យម ធំ។ ប៉ុន្តែក្រុមគាត់ពុំទាន់យល់ដឹងច្បាស់ពីប្រភេទពូជដំណាំប័រដែលត្រូវជ្រើសរើសសម្រាប់ធ្វើការដាំដុះនៅឡើយ គឺមានការដាំពូជចំរុះច្រើនដោយនិយមដាំតាមគ្នាដោយពុំបានគិតពីតម្រូវការទីផ្សារ។ យោងតាមការសិក្សាស្រាវជ្រាវនៃគម្រោងកម្មវិធីខ្សែច្រវាក់តម្លៃកសិកម្មកម្ពុជា-អូស្ត្រាលី ហៅកាត់ថា (CAVAC) ដែលបានសហការជាមួយអគ្គនាយកដ្ឋានកសិកម្ម បានបង្ហាញថា ពូជដំណាំប័រដែលសមស្របសម្រាប់ការធ្វើផលិតកម្មល្អទាំង គុណភាព និងតម្លៃខ្ពស់នៅទីផ្សារក្នុងនិងក្រៅប្រទេសនោះគឺមានពូជហាស(Hass)។ អាស្រ័យដូចបានជម្រាបជូនខាងលើ និងដើម្បីជៀសវាងការខាតបង់ពេលវេលា ចំណាយថវិកាច្រើនពុំមានប្រសិទ្ធភាពសេដ្ឋកិច្ច និងផលិតផលគ្មានទីផ្សារនោះ នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ នៃអគ្គនាយកដ្ឋានកសិកម្ម សូមណែនាំជូនកសិករគួរប្រើពូជដែលបានស្រាវជ្រាវនិងពេញនិយមសម្រាប់ទីផ្សារក្នុងនិងក្រៅប្រទេសនាពេលបច្ចុប្បន្ន។



រូបទី១៖ ផ្លែប័រប្រភេទពូជ Hass

## ២ - សម្ភារសម្រាប់ប្រើ

- ចង់រុំគល់ទម្រ និងមែកត
- ស្បោងប្លាស្ទិច
- កាំបិត
- កៅស៊ូ




រូបទី២៖ សម្ភារសម្រាប់កាត់តមែក

## ៣ - ដើមគល់ទម្រ

គេអាចប្រើដើមដាំចេញពីគ្រាប់នៃពូជដែលគេស្គាល់ប្រភពសម្រាប់ធ្វើជាដើមគល់ទម្រ ដែលមានលក្ខណៈធន់នឹងសត្វល្អិតចង្រៃ និងមេរោគក្នុងដី។ ជាទូទៅគ្រាប់ប័រត្រូវការពេល ៤-៦សប្តាហ៍ដើម្បីដុះ និង ៤-៥ ខែ ដើម្បីឲ្យវាធំល្មមយកទៅតមែកបាន។



រូបទី៣៖ ដើមគល់ទម្រដំណាំប័របណ្តុះពីគ្រាប់

## ៤ - មែកសម្រាប់តជាមួយនឹងគល់ទម្រ

មែកសម្រាប់ត នឹងក្លាយជាផ្នែកដែលចេញផ្កា ផ្លែ ហើយមែកគួរតែជ្រើសរើសពីដើមប័រដែលគេចង់បាន។ មែកដែលល្អ គឺយកពីមែកដែលរឹង និងគ្មានជម្ងឺ។ ជ្រើសរើសមែកដែលមានពន្លកល្អ ហើយត្រូវមានយ៉ាងតិច ៣ពន្លក ត្រូវកាត់ប្រវែង ១០-១៥សង់ទីម៉ែត្រ បេះស្លឹកចេញ និងទុកមែកនោះនៅក្នុងក្រដាសសើម នៅក្នុងថង់ប្លាស្ទិច នៅកន្លែងត្រជាក់ រហូតដល់ពេលតមែក។



រូបទី៤៖ មែកប័រដែលកាត់ចេញពីដើមដែលគេចង់បាន

## អគ្គនាយកដ្ឋានកសិកម្ម

### នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ

អាសយដ្ឋាន : ផ្ទះលេខ៥៤B / ៥៩F ផ្លូវលេខ 395-656 សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ

ទូរស័ព្ទ : 017 437 129, 095 952 281

Fax : (855-23) 883 427

Email : Kean.sophea@gmail.com

http://www.gda.maff.gov.kh

ឆ្នាំ២០២១

រៀបចំដោយ៖ ការិយាល័យគ្រប់គ្រងពូជដំណាំ នៃនាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ

## ៥ - សង្ខេបវិធីសាស្រ្តការតមែកប័រជាមួយគល់ទម្រ

- ជ្រើសរើសមែកប័រដែលមានទំហំប្រហាក់ប្រហែលនឹងដើមជើងទម្រ ហើយត្រូវតមែកនៅក្នុងថ្ងៃតែមួយដែលគេកាត់មែកប័រនោះ។



រូបទី៥៖ មែកប័រទំហំប្រហែលដើមទម្រ

- កាត់ដើមគល់ទម្រ ឲ្យនៅប្រហែល ១៣ សង់ទីម៉ែត្រ ដើម្បីឲ្យមែកប័រដែលតនៅខ្ពស់ឆ្ងាយពីដី  ប៉ុន្តែមិនខ្ពស់ពេកដែលធ្វើឲ្យវាអាចខូចខាតដោយខ្យល់បក់។



រូបទី៦៖ ការកាត់ដើមគល់ទម្រ

- កាត់ជ្រៀកដើមគល់ទម្រចំកណ្តាល ឲ្យមានជម្រៅប្រហែល ២-៣សង់ទីម៉ែត្រ។



រូបទី៧៖ ការកាត់ជ្រៀកដើមជើងទម្រ

- កាត់មែកតជារាងអក្សរ V រួចរុញវាចូលក្នុងស្នាមកាត់នៃគល់ទម្រ ឲ្យសំបកខាងក្រៅរបស់មែកត និងគល់ទម្រវាស៊ីគ្នា។



រូបទី៨៖ ការស៊កមែកតចូលក្នុងគល់ទម្រជ្រៀករួច

- រុំកៅស៊ូកងជុំវិញកន្លែងតភ្ជាប់រវាងដើមគល់ទម្រ និងមែកប័រ។



រូបទី៩៖ ការរុំកៅស៊ូកងនៅកន្លែងភ្ជាប់មែកប័រ

- ប្រើថង់រុំជុំវិញកន្លែងតមែក ដោយរុំវាឲ្យជិត ដើម្បីរក្សាសំណើមកន្លែងត និងធ្វើអោយការតមែកនោះទទួលបានជោគជ័យ។ នៅពេលដែល កន្លែងតមែកជាប់គ្នានោះដើមទម្រនឹងផ្តល់ទឹក និងសារធាតុចិញ្ចឹមទៅឲ្យមែកដែលត។



រូបទី១០៖ ការរុំថង់ជុំវិញប័រដែលតរួច

- បន្ទាប់ពីតមែករួច ត្រូវស្រោចទឹកវាអោយបានល្អ និងរក្សាទុកវានៅកន្លែងដែលម្លប់បន្តិច។ វាត្រូវការរយៈពេលប្រហែលពី ៤-៦ សប្តាហ៍ ដើម្បីការតភ្ជាប់បានជោគជ័យ ដែលនៅពេលនោះអ្នកនឹងឃើញពន្លកថ្មីដុះចេញមក។